ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. 770 MOC / SM 2008

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីសុំសិទ្ធិនាំចេញក្រោមគំរោងអនុគ្រោះពន្ធសំរាប់សហគ្រាសសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម .
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម .
- គោលបំណងបង្កលក្ខណៈងាយស្រួល និង ជំរុញការអភិវឌ្ឍន៍ចំពោះសគ្រាសសិប្បកម្មនៅតាមបណ្តាខេត្ត-ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា ។

## សំរេច

**ប្រការ ១ :** ត្រូវបានអនុញ្ញាតអោយមន្ទីរពាណិជ្ជកម្មតាមបណ្តាខេត្ត-ក្រុងធ្វើការចុះបញ្ជីផ្តល់សិទ្ធិនាំចេញក្រោមគំរោងអនុគ្រោះពន្ធជូនសហគ្រាសសិប្បកម្មទាំងឡាយដែលបោះទីតាំងក្នុងមូលដ្ឋានរបស់ខ្លួន ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៨ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

Downloaded from http://www.khmerlaws.com

**ប្រការ ២ :** សំណុំឯកសារចាំបាច់សំរាប់ចុះបញ្ជីខាងលើមាន :

+ ពាក្យស្នើសុំតាមគំរូឯកភាពមួយ
+ វិញ្ញាបនប័ត្រ ឬ លិខិតអនុញ្ញាតពីក្រសួងពាក់ព័ន្ធ (ច្បាប់ដើម ឬថតចំលងដោយមានប្រថាប់ត្រាខេត្ត-ក្រុង)
+ លិខិតបញ្ជាក់ និងវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម (ច្បាប់ដើម ឬថតចំលងដោយមានប្រថាប់ត្រាខេត្ត-ក្រុង)
+ លក្ខន្តិកៈក្រុមហ៊ុន (ច្បាប់ដើម ឬថតចំលងដោយមានប្រថាប់ត្រាខេត្ត-ក្រុង)
+ ប័ណ្ណប៉ាតង់ (ច្បាប់ដើម ឬថតចំលងដោយមានប្រថាប់ត្រាខេត្ត-ក្រុង)
+ កិច្ចសន្យាជួល ឬប័ណ្ណកម្មសិទ្ធិទីស្នាក់ការ-រោងសិប្បកម្ម (ច្បាប់ដើម ឬថតចំលងដោយមានប្រថាប់ត្រាខេត្ត-ក្រុង)
+ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែនដែលមានសុពលភាពលើសពីមួយឆ្នាំ និង រូបថត ៤ x ៦ ពីរសន្លឹក
+ រូបថតទីស្នាក់ការ - រោងសិប្បកម្ម សង្វាក់ផលិតកម្ម និង ផលិតផលដែលត្រូវនាំចេញ

**ប្រការ ៣ :** មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងត្រូវចុះពិនិត្យទីតាំងផលិតកម្ម និង ផលិតផលអោយបានត្រឹមត្រូវ ត្រៀមបំភ្លឺជូនស្ថាប័នត្រួតពិនិត្យដែលមានភារកិច្ចពាក់ព័ន្ធ ។

**ប្រការ ៤ :** សហគ្រាសសិប្បកម្មត្រូវបង់កំរៃចុះបញ្ជីជូនមន្ទីរពាណិជ្ជកម្មដែលមានតំលៃស្មើនឹង ប្រាំពាន់រៀលសំរាប់ការចុះបញ្ជីមួយលើក ។

**ប្រការ ៥ :** ក្រោយពីបានទទួលរាល់សំណុំឯកសារចាំបាច់ និងបានចុះពិនិត្យមូលដ្ឋានផលិតកម្មរួចហើយ មន្ទីរពាណិជ្ជកម្មត្រូវផ្តល់ជូនសហគ្រាសសិប្បកម្មនូវវិញ្ញាបនប័ត្របណ្តោះអាសន្នមួយដែលមានសុពលភាពរយៈពេលពីរខែ ។

**ប្រការ ៦ :** មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងត្រូវពិនិត្យផ្ទៀងផ្ទាត់សំណុំឯកសារខាងលើអោយបានគ្រប់គ្រាន់ និង ត្រឹមត្រូវ រួចហើយបញ្ជូនសំណុំឯកសារទាំងនោះមកអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិនៃក្រសួងពាណិជ្ជកម្មដើម្បីបំពេញបែបបទស្នើសុំសេចក្តីសំរេចពីក្រសួងក្នុងការផ្តល់វិញ្ញាបនប័ត្រទទួលបានសិទ្ធិនាំចេញក្រោមគំរោងអនុគ្រោះពន្ធ ដែលមានសុពលភាពរយៈពេល ១២ ខែ ។

**ប្រការ ៧ :** ករណីសហគ្រាសខាងលើមានបំណងចង់នាំចេញបន្ត គឺត្រូវមកចុះបញ្ជីឡើងវិញ ស្របតាមប្រការ ២ នៃសេចក្តីប្រកាសលេខ ០១៤ ពណ.បអពប្រក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ១៩៩៨ ។

**ប្រការ ៨ :** នាយិកាខុទ្ទកាល័យ អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការ ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេរភាគី ប្រធាននាយកដ្ឋានពាណិជកម្មពហុភាគី ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ [illegible]
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

Downloaded from http://www.khmerlaws.com

និងហិរញ្ញវត្ថុ ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>**ចម្លងជូន :**</u>

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ដូចក្នុងប្រការ ៨
- ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៨ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៨១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

Downloaded from http://www.khmerlaws.com